ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៤៧/១១-ហុងវ៉ា
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **សេង រ៉ូចហ៊ុន**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អាន វីរៈ**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ធីរីង លីមីធីត**
អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៧២៦ ១១៣ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

១- លោក ចាន់ វ៉ែន នាយកក្រុមហ៊ុន
២- លោក ហេង សុខា រដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖- **សហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ ហុងវ៉ា**
- **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

អាសយដ្ឋាន ៖ ផ្ទះលេខ ២៨ បេ (B) ផ្លូវ ២២២ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៩៣៥ ៤៩៦ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត:

១- លោក ម៉ាន់ សេងហាក់ មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

| | |
|---|---|
| ២- លោកស្រី ទូច សើ | ប្រធានសហជីពសេរីកម្មករប្រចាំរោងចក្រ |
| ៣- លោក ហ៊ល សុគន្ធ | តំណាងកម្មករ |
| ៤- លោក អ៊ុន សុខសីហា | តំណាងកម្មករ |
| ៥- លោកស្រី ឃុត សុវណ្ណ | តំណាងកម្មករ |
| ៦- លោកស្រី ងិន ស៊ីនួន | តំណាងកម្មករ |
| ៧- លោកស្រី ម៉ៅ គីមហួយ | តំណាងកម្មករ |
| ៨- លោកស្រី អឹម ទូច | តំណាងកម្មករ |
| ៩- លោកស្រី ប៉ែន ស៊ីម៉ី | តំណាងកម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់លើកទឹកចិត្តចំនួនបីដុល្លារក្នុងមួយខែ ចំពោះកម្មករផ្នែកត្រែន ផ្នែកបម្រើការ និងផ្នែកពិនិត្យឱ្យបានដូចកម្មករផ្នែកដេរដែរ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះកម្មករផ្នែកត្រែន ផ្នែកបម្រើការ និងផ្នែកពិនិត្យ ក្រុមហ៊ុនដាក់ចេញគោលការណ៍ផ្តល់រង្វាន់លើកទឹកចិត្ត ដល់កម្មករ ដែលធ្វើការលើសចំនួនកំណត់របស់ក្រុមហ៊ុនដាក់ឱ្យនោះត្រូវទទួលបានក្នុងម្នាក់ចំនួន ៥០០ រៀល ១០០០ រៀល និង ២០០០ រៀល តាមផ្នែកនីមួយៗ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១២៤៩ កប/អក/វក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យតន្ត្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក)។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា លេខ ៣៩៤/១១ សសកពក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ១២៤៩ កប/អក/វក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ០៨៖៣០នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០១ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តី សម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះជាសេចក្តីសម្រេច ដែលជាប់កាតព្វកិច្ចតាមរយៈអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេច របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីប្រយោជន៍នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ច ក្នុងការអនុវត្តសេចក្តីសម្រេច ដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃ អនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។ ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសយកសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីប្រយោជន៍។ ភាគីនៃសំណុំរឿងនេះបានឯកភាពពន្យាពេលនៃការចេញសេចក្តីបង្គាប់រហូតដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

**តស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- សារណាសង្ខេបទាក់ទងនឹងវិវាទ ។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ហុងវ៉ា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ហុងវ៉ា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៤ ។

៤- លិខិតបញ្ជាក់នៃការផ្តល់ជូនប្រាក់លើមធ្យោបាយធ្វើដំណើរចំនួន ៣ ដុល្លារកន្លងមក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ ។

៥- លក្ខន្តិកៈក្រុមហ៊ុន ហុងវ៉ា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាលេខ ៣៩៤/១១ សសកពក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ ស្តីពីការប្តឹងនាយកក្រុមហ៊ុនកាត់ដេរ ហុង វ៉ា ស្តីពីការមិនផ្តល់ប្រាក់លើកទឹកចិត្តចំនួន ៣ ដុល្លា ។

២- លិខិតពឹងពាក់របស់តំណាងសហជីព និងតំណាងកម្មករ រួមទាំងកម្មករ-កម្មការិនីបំរើការងារនៅក្រុមហ៊ុន ហុងវ៉ា គោរពជូន លោកប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការសុំជួយដោះស្រាយអំពីបញ្ហាក្រុមហ៊ុនមិនអនុវត្តកិច្ចព្រមព្រៀង ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១ ។

៣- វិញ្ញាបនប័ត្រសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ ហុងវ៉ា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ ។

៤- លក្ខន្តិកៈសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ ហុងវ៉ា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ ។

៥- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥ និង ៣៦ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហុងវ៉ា លេខ ១២៤៩ កប/អក/វក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ហុងវ៉ា ចុះថ្ងៃទី២៨ ខែ តុលា ឆ្នាំ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៨២៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៨៣០ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០១១ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ហុង វ៉ា មានជួលកម្មករនិយោជិតចំនួន ២២០០ នាក់។
- សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះមានសមាជិកចំនួន ១៥០ នាក់។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតដែលទាមទារចំណុចនេះ មានចំនួនជាង ១០០០ នាក់។
- យោងតាមបញ្ជីរឈ្មោះ ដែលផ្តល់ដោយភាគីកម្មករនិយោជិតនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានកម្មករនិយោជិតចំនួនតែ ៩៣៥ នាក់ទេ ដែលបានធ្វើលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ធ្វើជាតំណាងក្នុងការដោះស្រាយ។ ក្រុមហ៊ុនក៏មិនបានជំទាស់នឹងស្នាមមេដៃនេះដែរ។

**ចំណុចវិវាទ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់លើកទឹកចិត្តចំនួនបីដុល្លារអាមេរិកក្នុងមួយខែចំពោះកម្មករនិយោជិតផ្នែកត្រេន ផ្នែកបម្រើយការ និងផ្នែកពិនិត្យឱ្យបានដូចផ្នែកដេរដែរ**

- ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់លើកទឹកចិត្តចំនួន៣ដុល្លារអាមេរិកក្នុងមួយខែចំពោះកម្មករនិយោជិតផ្នែកត្រេន ផ្នែកបម្រើយការ និងផ្នែកពិនិត្យឱ្យបានដូចផ្នែកដេរដែរ។
- ភាគីនិយោជកបញ្ជាក់ថា ប្រាក់ចំនួន៣ដុល្លារអាមេរិកក្នុងមួយខែនេះ មិនមែនជាប្រាក់លើកទឹកចិត្តទេ គឺសម្រាប់កម្មករនិយោជិតដេរស៊ីបុង ដែលមិនទទួលបានប្រាក់ទ្រទ្រង់ជីវភាពចំនួន ៦ ដុល្លារអាមេរិក ហើយប្រាក់រង្វាន់លើកទឹកចិត្តនេះ ពួកគាត់ទទួលបានលុះត្រាតែពួកគេធ្វើការលើសចំនួនកំណត់ ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតផ្នែកដេរទទួលបានប្រាក់ចំនួន៣ដុល្លារអាមេរិកក្នុងមួយខែនេះ ប្រហែលជិតមួយឆ្នាំហើយ។

**កម្មករនិយោជិតផ្នែកត្រេន ÷**

- ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតផ្នែកត្រេន គឺជាកម្មករចល័ត មានជំនាញច្រើន ធ្វើការ

បានច្រើនប្រភេទ លើកលែងតែផ្នែកដេរ។ កម្មករនិយោជិតផ្នែកត្រេន មិនមែនជាកម្មករនិយោជិតដេរស៊ីបុងទេ។

- កម្មករនិយោជិតផ្នែកត្រេន គឺពួកគាត់ធ្វើការលើគូសសន្ទះកអាវ អ៊ុត កាត់ ចុះឡេវ វាយឡេវ កែអាវរួចហើយបញ្ជូនមកផ្នែកដេរ ដើម្បីដេរ។

កម្មករនិយោជិតផ្នែកបម្រើយការ និងផ្នែកពិនិត្យ ÷

- ភាគីកម្មនិយោជិតបញ្ជាក់ថា កម្មករនិយោជិតផ្នែកបម្រើយការ គឺពួកគាត់ធ្វើលើការកាត់ជេស អ៊ុត និងវេចខ្ចប់។ ចំណែកកម្មករនិយោជិតផ្នែកពិនិត្យ គឺពួកគាត់ធ្វើការលើការពិនិត្យទៅលើលទ្ធផលចុងក្រោយ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា សព្វថ្ងៃកម្មករនិយោជិតផ្នែកត្រេន ផ្នែកបម្រើយការ និងផ្នែកពិនិត្យទទួលប្រាក់ឈ្នួលគោលចំនួន ៦១ ដុល្លារអាមេរិក ប្រាក់រង្វាន់អតីតភាព និងប្រាក់រង្វាន់ធ្វើការទៀងទាត់តែប៉ុណ្ណោះ។ ប៉ុន្តែ ពួកគាត់មិនបានទទួលប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែចំនួន៣ដុល្លារអាមេរិកក្នុងមួយខែ បើទោះបីជាពួកគេធ្វើការលើសចំនួនកំណត់ក៏ដោយ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតផ្នែកត្រេន ផ្នែកបម្រើយការ និងផ្នែកពិនិត្យខិតខំធ្វើការងារ ដូចកម្មករនិយោជិតផ្នែកដេរដែរ។ ប្រសិនបើគ្មានកម្មករនិយោជិតផ្នែកត្រេន ផ្នែកបម្រើយការ និងផ្នែកពិនិត្យទេ ទំនិញមិនអាចចេញបានទេ។
- ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែចំនួន៣ដុល្លារអាមេរិកក្នុងមួយខែដល់កម្មករនិយោជិតផ្នែកត្រេន ផ្នែកបម្រើយការ និងផ្នែកពិនិត្យ ឱ្យដូចជាកម្មករនិយោជិតផ្នែកដេរបានទេ ព្រោះកម្មករនិយោជិតផ្នែកដេរមិនបានទទួលប្រាក់ទ្រទ្រង់ជីវភាពចំនួន៦ដុល្លារអាមេរិកទេ គឺពួកគេធ្វើការស៊ីតាមបរិមាណបុង។
- ភាគីនិយោជកបានបន្ថែមថា និយោជកបានកំណត់ប្រាក់រង្វាន់លើកទឹកចិត្តថ្មីចំនួន៥០០រៀល ១០០០រៀល និង២០០០រៀលក្នុងមួយថ្ងៃ ហើយត្រូវបានអនុវត្តនៅតាមផ្នែកនីមួយៗក្នុងរយៈពេលជាង២ខែកន្លងមកនេះ ហើយនិយោជកមានបំណងអនុវត្តប្រាក់រង្វាន់លើកទឹកចិត្តនេះ សម្រាប់កម្មករនិយោជិតទាំងអស់តែម្តង។
- ភាគីកម្មករនិយោជិតផ្នែកត្រេន ផ្នែកបម្រើយការ និងផ្នែកពិនិត្យបានបញ្ជាក់ថា ចំណែកប្រាក់រង្វាន់លើកទឹកចិត្តចំនួន៥០០រៀល ១០០០រៀល និង២០០០រៀល ក្នុងមួយថ្ងៃត្រូវបានអនុវត្តតែតាមផ្នែកប៉ុណ្ណោះ។ ហើយពួកគេមិនឯកភាពទទួលយកប្រាក់រង្វាន់លើកទឹកចិត្តចំនួន៥០០រៀល ១០០០រៀល និង២០០០រៀលនេះទេ ប្រសិនបើពួកគេមិនទាន់បានទទួលប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែចំនួន ៣ ដុល្លារអាមេរិកក្នុងមួយខែ ដូចជាកម្មករនិយោជិតផ្នែកដេរ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា រដ្ឋធម្មនុញ្ញចែងថា ការងារដូចគ្នាទទួលបានប្រាក់ឈ្នួលដូចគ្នា។ ភាគីកម្មករនិយោជិតមិនចាំមាត្រាណាមួយដែលចែងពីចំណុចនេះទេ។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ ភាគីកម្មករនិយោជិតបានផ្តល់ភស្តុតាងទាក់ទងនឹងមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញ ដែលគាំទ្រការលើកឡើងរបស់កម្មករនិយោជិត។

**ហេតុផលនៃសេចក្តីសម្រេច ÷**

មុននឹងពិចារណាចំណុចវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើចំណុចវិវាទនេះ ជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយចែងពីការទាមទារនោះ"* ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *០៥/១១-អ៊ីម វើ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៧/១១-ហ្គួល កាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៨/១១-ជី អេច ជី ហេតុផល ចំណុចវិវាទទី៤)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ចំណុចវិវាទនេះ (ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៣ ដុល្លារអាមេរិក) គឺជាវិវាទអំពីសិទ្ធិ ព្រោះវិវាទទាំងនេះពាក់ព័ន្ធនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ស្តីពីការងារ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទនេះ ដូចខាងក្រោម ៖

ប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម...ឬដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

យោងតាមប្រការ១៩ នៃប្រកាសលេខ ៩៩/០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា "ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ" មានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួនក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាបុគ្គលនោះទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១៦១/០៩-សិប្បកម្មព្រែកព្រៃង និងលេខ ៤៣/១០-ម៉ឹង ជៀន*) ។

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាទទួលបានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិតចំនួន ៩៣៩ នាក់ ដើម្បីឱ្យសហជីពនេះធ្វើជាតំណាងក្នុងការដោះស្រាយវិវាទនេះ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពនេះមានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យកម្មករនិយោជិតចំនួន ៩៣៩ នាក់ ដើម្បីធ្វើការដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ចំពោះបញ្ហាស្នាមមេដៃពិត ឬក្លែងក្លាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានសមត្ថកិច្ចធ្វើកោសល្យវិច្ច័យទេ។ ចំណែកក្រុមហ៊ុនក៏មិនបានជំទាស់នឹងស្នាមមេដៃនេះដែរ ។

មាត្រា២ នៃច្បាប់ស្តីពីការងារចែងថា *"..... សហគ្រាសនីមួយៗ អាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក"* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅក្នុងសហគ្រាស ឬក្រុមហ៊ុនមួយ និយោជកមានសិទ្ធិគ្រប់គ្រងចាត់ចែងការងារ និងសម្រេចនូវគោលនយោបាយផ្សេងៗ លុះត្រាតែការចាត់ចែង និងសម្រេចនោះធ្វើឡើងទៅតាម

ច្បាប់ និងសមហេតុផល។ (សូមមើលសេចក្តីបង្គាប់សំណុំរឿងលេខ *០៦/០៦-អ៊ីម វ៉េ ចំណុចវិវាទទី១ និង លេខ ១០៨/០៦ -ទ្រីនុងហ្គាល កុមារា ចំណុចវិវាទទី ១*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។

ក្នុងករណីនេះ ភាគីកម្មនិយោជិតបញ្ជាក់ថា កម្មករនិយោជិតផ្នែកគ្រែន ផ្នែកបម្រើការ និងផ្នែកពិនិត្យជាកម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលគោល៦១ដុល្លារអាមេរិក ហើយធ្វើការងារដូចជាកម្មករនិយោជិតផ្នែកដេរដែរ។ ប៉ុន្តែ ពួកគាត់មិនទទួលបានប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៣ ដុល្លារអាមេរិកប្រចាំខែ ដូចកម្មករនិយោជិតផ្នែកដេរនោះទេ។ លើសពីនេះទៀត នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកថា រដ្ឋធម្មនុញ្ញចែងថា ការងារដូចគ្នាទទួលបានប្រាក់ឈ្នួលដូចគ្នា។

មាត្រា ៣៦ កថាខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញចែងថា *"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលបានប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា"*។

មាត្រា ១០៦ ចែងថា *"ចំពោះការងារដែលមានល័ក្ខខ័ណ្ឌស្មើគ្នា ភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈ និងផល ដែលធ្វើបានស្មើគ្នា ប្រាក់ឈ្នួលត្រូវឱ្យស្មើគ្នា ដល់កម្មករនិយោជិតទាំងអស់ដែលស្ថិតនៅក្រោមវិវាទច្បាប់នេះ ទោះមានដើមកំណើត ភេទ ឬ អាយុយ៉ាងណាក៏ដោយ"* ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុន ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រសិនបើមានភាពខុសគ្នាលើជំនាញវិជ្ជាជីវៈ ឬទិន្នផល ភាពខុសគ្នាទាំងនេះអាចទាក់ទងដល់ការកំណត់ប្រាក់ឈ្នួល និងអាចជាហេតុផលនៃភាពខុសគ្នានៃប្រាក់ឈ្នួលរបស់និយោជិត។ (សូមមើលសេចក្តីបង្គាប់សំណុំរឿងលេខ *៦៨/០៤-ស៊ីធីញូ ហេតុផលចំណុចវិវាទទី ២*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិតផ្នែកគ្រែន ផ្នែកបម្រើការ និងផ្នែកពិនិត្យមានជំនាញខុស និងធ្វើការងារផ្សេងគ្នាពីកម្មករនិយោជិតផ្នែកដេរ ហើយទិន្នផលដែលបានធ្វើក៏ខុសគ្នាដែរ។ ផ្អែកលើមូលដ្ឋាននេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ១០៦ នៃច្បាប់ស្តីពីការងារមិនអាចអនុវត្តបានទេនៅក្នុងករណីនេះទេ ដោយសារប្រភេទការងាររបស់កម្មករនិយោជិតផ្នែកគ្រែន ផ្នែកបម្រើការ ផ្នែកពិនិត្យ និងផ្នែកដេរគឺមិនស្មើគ្នា ភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈ និងផលដែលធ្វើបានក៏មិនស្មើគ្នាដែរ។ ដូចនេះ កម្មករនិយោជិតផ្នែកគ្រែន ផ្នែកបម្រើការ និងផ្នែកពិនិត្យមិនមានសិទ្ធទទួលបានប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៣ ដុល្លារអាមេរិកទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួនចំនួន ៣ ដុល្លារអាមេរិក ដល់កម្មករនិយោជិតផ្នែកគ្រែន ផ្នែកបម្រើការ និងផ្នែកពិនិត្យ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ ៖**

ចំណុចវិវាទ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ចំនួន ៣ ដុល្លារអាមេរិក ដល់កម្មករនិយោជិតផ្នែកគ្រេន ផ្នែកបម្រើយការ និងផ្នែកពិនិត្យ ។

**ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:**

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០ ។*

**២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖ គ្មាន**

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **សេង ទូចហ៊ុន**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា: ------------------------------------

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**
**ជម្រាបជូន**
**- លោកនាយកក្រុមហ៊ុន ហុង វ៉ា**
**- ប្រធានសហជីពសេរីកម្មករនៃក្រុមហ៊ុន ហុង វ៉ា**

**កម្មវត្ថុ:** សេចក្តីកែតម្រូវផ្នែកភស្តុតាង ត្រង់ទំព័រទី៤ ទាក់ទងនឹងឯកសារ វត្ថុតាង ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាល យកមកពិចារណា - ឯកសារដែលទទួលបានពីភាគីនិយោជក ចំណុចទី៤ នៃសំណុំរឿងលេខ ១៤៧/១១-ក្រុមហ៊ុន ហុង វ៉ា ដោយសារតែកំហុសបច្ចេកទេស។

**យោង:** សំណុំរឿងលេខ ១៤៧/១១-ហុង វ៉ា ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសូមធ្វើការបញ្ជាក់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនបានទទួលឯកសារត្រង់ចំណុចទី៤ ពីភាគីនិយោជកទេ។ ដូចនេះ ចំណុចទី៤ នៅក្នុងឯកសារ ដែលទទួលបានពីភាគីនិយោជក គឺមិនមានទេ។

**បញ្ជាក់:** ការកែប្រែនេះ មិនប៉ះពាល់ដល់អង្គសេចក្តី និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលចេញនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ទេ។

អាស្រ័យហេតុនេះ សូមលោកនាយកក្រុមហ៊ុន និង លោកស្រីប្រធានសហជីព មេត្តាអធ្យាស្រ័យចំពោះកំហុសបច្ចេកទេស ដូចបានរៀបរាប់ខាងលើ។

សេចក្តីកែតម្រូវនេះ នឹងរក្សាទុកនៅក្នុងសំណុំរឿងលេខ ១៤៧/១១-ហុង វ៉ា នៅឯលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១
ហត្ថលេខា
ក្រុមអាជ្ញាកណ្តាល

Am Vireak

គង់ ផល្លៈ | សេង រ៉ូចហ៊ុន | អាន វីរៈ

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org